**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សណ្ឋាគារ ញូ រីវើរ សាយ
NEW RIVERSIDE HOTEL

# កិច្ចព្រមព្រៀង
## ស្តីពីការព្យួរកិច្ចសន្យាការងាររវាងតំណាងកម្មករនិយោជិត និង និយោជក

ឆ្លងតាមការពិភាក្សាពន្យល់នូវគោលបំណងដែលពាក់ព័ន្ធនឹងការព្យួរការងារអោយបានសមស្របតាមសេចក្តីណែនាំលេខៈ ០៤៥/២០កប/ស.ណ.ន.ខ.ល ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០២០ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈគ្រប់ភាគីទាំងពីរបានឯកភាពយល់ព្រមព្យួរកិច្ចសន្យាការងារចំពោះកម្មករ។ដូច្នេះក្រុមហ៊ុនយើងខ្ញុំស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ចំនួន ៤៣នាក់ (ស្រី ២០នាក់)ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៤៥នាក់ (ស្រី ២០នាក់) រយៈពេល ៦០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០៥ ខែ កុម្ភៈ ឆ្នាំ២០២១ រហូតដល់ថ្ងៃទី០៥ ខែ មេសា ឆ្នាំ២០២១។ ដោយទទួលបាននូវប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលក្នុងម្នាក់ៗចំនួន៤០ដុល្លាអាមេរិចក្នុងរយៈពេលការព្យួរកិច្ចសន្យាការងារនេះ។ សំរាប់ក្រុមហ៊ុនមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់ប្រាក់ឧបត្ថម្ភ បន្ថែមទៅដល់បុគ្គលិក ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះឡើយ ដោយសារតែក្រុមហ៊ុនទទួលរងផលប៉ះពាល់ពីជំងឺ កូវីដ-១៩ (Covid-19)បាត់បង់ប្រាក់ចំណូល។

តាមការពិភាក្សានេះត្រូវបានបញ្ចប់នៅវេលាម៉ោង ១៤ និង ៣០នាទី នាថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០២១។ ដោយមានចុះហត្ថលេខាព្រមព្រៀងរបស់តំណាងទាំងអស់ដែលអាចយកជាការបានចំពោះមុខច្បាប់។

កិច្ចព្រមព្រៀងខាងលើបង្ហាញពីព័ត៌មានពិត និងត្រឹមត្រូវរវាងភាគីដែលបានចុះហត្ថលេខា/ស្នាមមេដៃដូចខាងក្រោម៖

សៀមរាប ថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០២១

| | |
|---|---|
| ភាគីតំណាងឲ្យនិយោជិត | ភាគីតំណាងឲ្យយោជក |
| ហត្ថលេខា/ស្នាមមេដៃ | ហត្ថលេខា/ស្នាមមេដៃ |

សណ្ឋាគារ ញូ រីវើរ សាយ
NEW RIVERSIDE HOTEL

Add: 1500m the east of Old Market, 7 Makara Road, Chunlong Village, Sala Kamroeuk Commune, Siem Reap City, Siem Reap Province, Kingdom of Cambodia
H/P: 012999952, 012 550055, Oficial Tel: +855 63 765533, Fax: +855 63761511, E-mail: rservation@newriversidehotel.com, Website: www.newriversidehotel.co